មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន

## ស្តីពីការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

## លក្ខខណ្ឌសម្រាប់គ្រូមូលដ្ឋាន ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន

*លក្ខខណ្ឌទូទៅ*

- លោកគ្រូអ្នកគ្រូត្រូវតែជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ហើយមានបទពិសោធន៍នៅក្នុងការបង្រៀនប្រវត្តិវិទ្យាយ៉ាងតិចចំនួន៣ឆ្នាំ ។ គ្រូមុខវិជ្ជាផ្សេង ឬបុគ្គលិកបម្រើការនៅក្នុងមន្ទីរមិនអាចចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះបានទេ ។
- មិនអនុញ្ញាតឲ្យមានការប្តូរឬផ្ទេរឈ្មោះ ។ ប្រសិនបើលោកគ្រូអ្នកគ្រូមិនបានអញ្ជើញមក លោកគ្រូអ្នកគ្រូនឹងមិនត្រូវបានអញ្ជើញឲ្យចូលរួម នៅក្នុងវគ្គក្រោយៗទៀតទេ ។
- ត្រូវចូលរួមវគ្គបណ្តុះបណ្តាលឲ្យបានពេញរយៈពេល៧ថ្ងៃ ។ អ្នកដែលអវត្តមានមួយថ្ងៃនឹងមិនទទួលបានវិញ្ញាបនបត្រទេ ។
- មិនត្រូវសរសេរកិច្ចតែងការបង្រៀន ឬធ្វើកិច្ចការផ្សេងៗទៀតក្នុងម៉ោងសិក្សា ។
- មិនត្រូវពិសារបារីនៅក្នុងបរិវេណបណ្តុះបណ្តាល ។
- សូមបិទសម្លេងទូរស័ព្ទក្នុងកំឡុងពេលបណ្តុះបណ្តាល ។
- សូមកុំជជែកគ្នាក្នុងកំឡុងពេលបណ្តុះបណ្តាល ។
- អញ្ជើញមកទីតាំងបណ្តុះបណ្តាលឲ្យបានទៀតទាត់ តាមពេលវេលាដែលបានកំណត់ ។
- សូមអាន (១) សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (២) សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និង (៣) ឯកសារបណ្តុះបណ្តាលផ្សេងៗទៀតឲ្យបានចប់សព្វគ្រប់ មុនអញ្ជើញមកចូលរួមក្នុងការបណ្តុះបណ្តាល ។
- សូមអានកម្មវិធីបណ្តុះបណ្តាលសម្រាប់ថ្ងៃនីមួយៗឲ្យបានយល់ច្បាស់ ។
- គោរពគ្នាទៅវិញទៅមកនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល ។
- ត្រូវគោរពសិទ្ធិរបស់ស្ត្រី ។ មិនត្រូវនិយាយឬសំដែងកាយវិការណាមួយ ដែលមានលក្ខណៈមើលងាយឬមានលក្ខណៈជាការបៀតបៀនផ្លូវភេទ ។
- ត្រូវគោរពចំពោះសិទ្ធិរបស់អ្នកដែលគោរពជំនឿសាសនាផ្សេងៗគ្នា និងជៀសវាងសកម្មភាពឬកាយវិការ ដែលមានលក្ខណៈជាការរើសអើងពូជសាសន៍ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

- ត្រូវមានការទទួលខុសត្រូវ និងគោរពវិន័យ ។

## ថវិកាឧបត្ថម្ភ

- មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលខុសត្រូវ ក្នុងការចំណាយទៅលើថ្លៃធ្វើដំណើរ ដែលមិនអាចមានភាពសុក្រិត ឬដូចគ្នាបានមួយរយភាគរយនោះទេ ។ លោកគ្រូអ្នកគ្រូទទួលបានថវិកាបន្ថែមសម្រាប់ការស្នាក់នៅនិងការហូបចុក ចំនួន៧ដុល្លាសហរដ្ឋអាមេរិកក្នុងមួយថ្ងៃសម្រាប់គ្រូនៅទីរួមខេត្ត និង១០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយថ្ងៃសម្រាប់គ្រូមកពីស្រុកផ្សេងៗក្រៅពីទីរួមខេត្ត ។
- ថវិកានឹងត្រូវបានបើកជូនសម្រាប់រយៈពេល៧ថ្ងៃពេញ ។
- ថវិកាដែលផ្តល់ជូន គឺដើម្បីជួយទ្រទ្រង់ដល់ការស្នាក់នៅនិងការបំពេញបេសកកម្មរបស់លោកគ្រូអ្នកគ្រូ មិនមែនជាការប្រើប្រាស់ថវិការដើម្បីអញ្ជើញលោកគ្រូអ្នកគ្រូឲ្យចូលរួមសិក្ខាសាលា ឬជាថ្នូរនឹងចំណេះដឹងឬបទពិសោធន៍តាមរយៈសិក្ខាសាលានេះទេ ។
- ថវិកានឹងត្រូវបានបើកជូននៅថ្ងៃចុងក្រោយនៃវគ្គបណ្តុះបណ្តាល ។

***បញ្ជាក់*** ៖ *សូមលោកគ្រូអ្នកគ្រូយកមកជាមួយនូវរូបថត ៤X៦ ចំនួន១សន្លឹក ដោយមានសរសេរឈ្មោះនិងឯកទេសបង្រៀននៅខាងក្រោយខ្នងរូបថត ដើម្បីធ្វើវិញ្ញាបនបត្រ ។*

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលោក វ៉ាន់ថាន់ ពៅដារ៉ា ០១២ ៨៤៦ ៥២៦ ។***